ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ
លេខ : ២០៨៦ មស.សង៣

# សេចក្តីជូនដំណឹង

ផ្អែកតាមផែនការមេសម្រាប់យុទ្ធនាការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ក្នុងក្របខ័ណ្ឌទូទាំងប្រទេស ប្រជាពលរដ្ឋទាំងអស់ដែលមានអាយុចាប់ពី១៨ឆ្នាំឡើងទៅក្នុងរាជធានីភ្នំពេញនឹងទទួលបានការចាក់វ៉ាក់សាំងគ្រប់ៗគ្នាទៅតាមជំហានកម្មវិធី និងទីតាំង ដែលកំណត់ដោយគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខ័ណ្ឌទូទាំងប្រទេស និងរដ្ឋបាលរាជធានីភ្នំពេញ។ ក្នុងន័យនេះ ការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩នឹងប្រព្រឹត្តទៅនៅតាមមូលដ្ឋានដែលប្រជាពលរដ្ឋកំពុងរស់នៅ រីឯការចាក់វ៉ាក់សាំងរៀបចំក្នុងក្របខ័ណ្ឌក្រសួងមុខងារសាធារណៈគឺ**ពុំមានទៀតឡើយ**។

ដោយហេតុនេះ សូម **ឯកឧត្តម លោកជំទាវ លោក លោកស្រីទាំងអស់ ជាថ្នាក់ដឹកនាំក្រសួង ទីប្រឹក្សាក្រសួង មន្ត្រីរាជការ មន្ត្រីជាប់កិច្ចសន្យា និងសមាជិកក្រុមគ្រួសារទាំងអស់** ដែលមិនទាន់បានចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ មេត្តាទំនាក់ទំនងជាមួយអាជ្ញាធរមូលដ្ឋានដែលខ្លួនកំពុងរស់នៅដើម្បីទទួលបានការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩។

ជាមួយគ្នានេះ សូម **ឯកឧត្តម អគ្គនាយក អគ្គាធិការ នាយកសាលាភូមិន្ទរដ្ឋបាល និងប្រធានអង្គភាពថ្នាក់ស្មើទាំងអស់** មេត្តាជំរុញ និងសម្របសម្រួលឱ្យមន្ត្រីក្រោមឱវាទ និងសមាជិកក្រុមគ្រួសារទាំងអស់បានចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ហើយរាយការណ៍អំពីលទ្ធផលនៃការទទួលបានការចាក់វ៉ាក់សាំងជូនក្រសួង។

អាស្រ័យហេតុនេះ សូម **ឯកឧត្តម លោកជំទាវ លោក លោកស្រីទាំងអស់** មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃ ចន្ទ ១៣កើត ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២១

**រដ្ឋលេខាធិការ**
ប្រធានអនុគណៈកម្មការចាក់វ៉ាក់សាំងកូវីដ-១៩
របស់ក្រសួងមុខងារសាធារណៈ

**អែម ប៊ុនថុល**